**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០២០/២៥ ន. គ. ស/គ.ស.ស.

ថ្ងៃសុក្រ ៤ កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា គ.ស.២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើទម្រង់ពាក្យស្នើសុំសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម** (**ន.គ.ស**) **នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) មានកិត្តិយសសូមជម្រាបជូន ម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ (អង្គភាព) ជ្រាបថា៖ យោងប្រកាសលេខ០០២ អ.ស.ហ.ប្រក. ចុះថ្ងៃទី១៥ ខែមករា គ.ស.២០២៥ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម **ន.គ.ស**. បានរៀបចំនូវទម្រង់ពាក្យស្នើសុំសេវាសាធារណៈរបស់ **ន.គ.ស**. ដើម្បីសម្របសម្រួលដល់សហគ្រាស និងអង្គភាពក្នុងការស្នើសុំសេវាសាធារណៈដែលមានដូចខាងក្រោម៖

១. សេវាស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
២. សេវាស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងារសវនកម្មឯករាជ្យ
៣. លិខិតអនុញ្ញាតបដិប្បញ្ញត្តិក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ
៤. លិខិតអនុញ្ញាតផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ
៥. ការស្នើសុំផ្លាស់ប្តូរគណនីប្រើប្រាស់ក្នុងប្រព័ន្ធ E-Filing
៦. កែតម្រូវព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ
៧. លិខិតបញ្ជាក់បច្ចុប្បន្នភាពព័ត៌មានសហគ្រាស

សហគ្រាស និងអង្គភាពអាចទាញយកទម្រង់ពាក្យស្នើសុំសេវាសាធារណៈ ដោយចូលទៅកាន់គេហទំព័ររបស់ **ន.គ.ស**. តាមរយៈតំណភ្ជាប់ https://www.acar.gov.kh រួចទាញយកទម្រង់ពាក្យស្នើសុំនៅផ្នែកខាងស្តាំនៃគេហទំព័រដែលមានចំណងជើង «ពាក្យស្នើសុំសេវាសាធារណៈ» ឬស្កេនយូអរកូដខាងក្រោម។ សហគ្រាស និងអង្គភាពដែលស្នើសុំសេវាសាធារណៈរបស់ **ន.គ.ស**. ត្រូវបំពេញពាក្យស្នើសុំជាទម្រង់ PDF ដោយប្រើកុំព្យូទ័រ រួចបោះពុម្ព ចុះហត្ថលេខា បោះត្រា និងបង់កម្រៃសេវាសាធារណៈយោងតាមប្រកាសលេខ០០២ អ.ស.ហ.ប្រក. ចុះថ្ងៃទី១៥ ខែមករា គ.ស.២០២៥ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម ហើយដាក់ពាក្យស្នើសុំមក **ន.គ.ស**. ដោយផ្ទាល់ជាមួយឯកសារភ្ជាប់ដូចមានបញ្ជាក់ជូនក្នុងឧបសម្ព័ន្ធនៃពាក្យស្នើសុំនីមួយៗ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាព ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

គេហទំព័ររបស់ **ន.គ.ស**.

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111
អ៊ីមែល : info@acar.gov.kh